Khmer

# កូនក្មេងពុំចេះហោះឡើយ

## ការពារការធ្លាក់ពីបង្អួច និងរានហាល

**ចំនួនកូនក្មេងចូលព្យាបាលនៅមន្ទីរពេទ្យកើនឡើងជារៀងរាល់ឆ្នាំដោយសារការធ្លាក់ពីបង្អួច និងរានហាល។ ការធ្លាក់ទាំងនេះ ជាញឹកញាប់កើតមានក្នុងផ្ទះរបស់កូនក្មេងផ្ទាល់ ហើយអាចបណ្តាលឲ្យស្លាប់ និងរងរបួសយ៉ាងធ្ងន់ធ្ងរ។**

កូនក្មេងអាយុចាប់ពីមួយ ទៅប្រាំឆ្នាំភាគច្រើនប្រឈមមុខនឹងគ្រោះថ្នាក់ ដោយសារគេចង់ដឹងចង់ឃើញច្រើនតាមធម្មតា ក៏ប៉ុន្តែគេខ្វះនូវសមត្ថភាពនឹងសំគាល់គ្រោះថ្នាក់។ ការធ្លាក់កើតមានភាគច្រើននៅក្នុងខែក្តៅខ្លាំង នៅពេលគ្រួសារទុកបង្អួច និងទ្វារចេញទៅរានហាលបើកចំហចោលក្នុងអំឡុងពេលថ្ងៃ និងយប់។

ច្បាប់សំណង់នៃប្រទេសអូស្ត្រាលី អនុញ្ញាតឲ្យមានចំហធំបំផុតត្រឹម១២.៥សង្ទីម៉ែត្រសំរាប់បង្អួច និងបង្កាន់ដៃ(កន្លែងដែលត្រូវបានដាក់បទបញ្ញត្តិ)។ សូមកត់សំគាល់ថាពុំមានច្បាប់ដែលតម្រូវឲ្យមានចំហបង្អួច និងបង្កាន់ដៃក្នុងអគារចាស់ៗ បំពេញទៅតាមបទដ្ឋានសំណង់ឡើយ។ ទោះបីយ៉ាងនេះក្តីមានកិច្ចការជាច្រើនដែលលោកអ្នកអាចធ្វើបាន ដើម្បីឲ្យសុវត្ថិភាពបានប្រសើរឡើង។

ប្រសិនបើលោកអ្នករស់នៅតាមផ្ទះជួល សូមឲ្យប្រាកដច្បាស់ថាលោកអ្នកបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរ ពីម្ចាស់ផ្ទះរបស់លោកអ្នកមុននឹងដាក់គ្រឿងសង្ហារឹមបន្ថែម ឬធ្វើការកែប្រែផ្ទះរបស់លោកអ្នក។ តាមច្បាប់ ម្ចាស់ផ្ទះពុំអាចបដិសេធដោយពុំសមហេតុផលចំពោះអ្នកជួលផ្ទះដើម្បីធ្វើការកែប្រែបន្តិចបន្តួច ដូចជាការតម្លើងឧបករណ៍សុវត្ថិភាពនៅតាមបង្អួច ឬកែប្រែលក្ខណៈពិសេសសំរាប់សន្តិសុខដទៃទៀតជាដើម។





ចំពោះពត៌មានបន្ថែម និងសេចក្តីដែលបានបកប្រែភាសា សូមបើកមើលវិបសាយៈ

**www.health.nsw.gov.au/childsafety**

NSW

the children's hospital at Westmead

# កូនក្មេងពុំចេះហោះឡើយ

## ការពារការធ្លាក់ពីបង្អួច និងរានហាល

### សុវត្ថិភាពនៅតាមបង្អួច

កូនក្មេងអាចធ្លាក់ចេញក្រៅបង្អួច ដែលបើកចំហធំជាង១២.៥សង្ទីម៉ែត្រ ទោះបីជាបានដាក់ផ្ទាំងសំណាញ់ការពាររុយក៏ដោយ។

**ដើម្បីការពារកូនក្មេងកុំឲ្យធ្លាក់ពីបង្អួចរបស់លោកអ្នក នេះត្រូវបានណែនាំថា:**

- នៅកន្លែងដែលអាចធ្វើបាន បង្អួចទាំងអស់ ជាពិសេសបង្អួចនៅតាមបន្ទប់ដេក:
  - ត្រូវបើកចំហកុំឲ្យធំជាង១២.៥សង្ទីម៉ែត្រ ពេលណាដាក់នៅខាងលើជាន់ក្រោមបង្អស់។
  - មានដាក់គន្លឹះ /សោចាក់ដើម្បីទប់កុំឲ្យបង្អួចបើកចំហធំជាង១២.៥សង្ទីម៉ែត្រ ឬដាក់ព្រនង់ខ្នាស់ ដើម្បីការពារការបើកចំហ (សូមមើល **កូនក្មេងពុំចេះហោះឡើយ** សេចក្តីណែនាំអំពីផលិតផលសុវត្ថិភាពដាក់នៅតាមបង្អួច)។
  - បើកបង្អួចពីខាងលើ។
- គ្រែ និងគ្រឿងសង្ហារឹមដទៃទៀតត្រូវបានទុកឆ្ងាយពីបង្អួច ដើម្បីកុំឲ្យកូនក្មេងអាចប្រើវាសំរាប់តោងឡើងទៅបង្អួច។
- សូមលោកអ្នកកុំទុកចិត្តលើផ្ទាំងសំណាញ់ការពាររុយ ដើម្បីទប់ស្កាត់កុំឲ្យកូនក្មេងធ្លាក់ក្រៅបង្អួចឡើយ។
- កូនក្មេងត្រូវបានបង្ហាត់ឲ្យលេងឆ្ងាយពីបង្អួច។
- កូនក្មេងត្រូវបានត្រួតមើលជាប្រចាំ។

### សុវត្ថិភាពនៅតាមរានហាល

**ដើម្បីទប់ស្កាត់កូនក្មេងកុំឲ្យធ្លាក់ពីរានហាលរបស់លោកអ្នក នេះត្រូវបានណែនាំថា:**

- កន្លែងដែលអាចធ្វើបាន បង្កាន់ដៃ(របងការពារ) ត្រូវ:
  - មានកំពស់យ៉ាងតិច១ម៉ែត្រ។
  - មានរបាំងការពារបញ្ឈរដែលឃ្លាតពីគ្នាពុំធំជាង១២.៥សង្ទីម៉ែត្រឡើយ (សូមប្រើបន្ទាត់ដើម្បីវាស់ប្រវែងគម្លាតរវាងបង្គោលបង្កាន់ដៃបញ្ឈររបស់លោកអ្នក)។
  - ពុំមានវត្ថុដាក់ផ្តេក ឬស្ទើរផ្តេកដែលនឹងអនុញ្ញាតឲ្យកូនក្មេងតោងឡើងឡើយ។
- គ្រឿងសង្ហារឹមទាំងអស់ ផើងរុក្ខជាតិ និងវត្ថុដែលកូនក្មេងអាចតោងឡើងត្រូវបានទុកឲ្យឆ្ងាយពីគែមរានហាល។
- លោកអ្នកត្រូវប្រុងប្រយ័ត្នអំពីគ្រឿងសង្ហារឹមដែលស្រាលល្មម ដែលអាចឲ្យកូនក្មេងទាញដាក់ទៅគែមរានហាល។
- ចាក់សោទ្វារដែលនាំទៅដល់រានហាល ដើម្បីទប់ស្កាត់កុំឲ្យកូនក្មេងចូលទៅដល់រានហាល។
- កូនក្មេងត្រូវបានត្រួតមើលជាប្រចាំ។





ចំពោះព័ត៌មានបន្ថែម និងសេចក្តីដែលបានបកប្រែភាសា សូមបើកមើលវិបសាយ:

**www.health.nsw.gov.au/childsafety**

the children's hospital at Westmead

November 2012 © NSW Health SHPN Khmer (CPH) 120385